**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៤០ . សសរ**

# សេចក្តីសំរេច

## ស្តីពីការបន្ថែមភារកិច្ចជូនឧបនាយករដ្ឋមន្ត្រី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ១៩ សសរ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ ស្តីពី របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ ១ :** ត្រូវបានបន្ថែមភារកិច្ចជូន ឯកឧត្តម កែ គឹមយ៉ាន ឱ្យទទួលជួយនាយករដ្ឋមន្ត្រី លើការងារប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ និងការងារនីតិសម្បទាចំពោះជនរងគ្រោះដោយសារគ្រឿងញៀន ។

**ប្រការ ២ :** ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ,ស្ថាប័នត្រូវអនុវត្តតាមសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី*
- *ដូចប្រការ ១*
- *ឯកសារ-កាលប្បវត្តិ*